**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ:.......✓.............អ.ជ.ប.ជ.អ

# សេចក្តីប្រកាសព័ត៌មាន

កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីរបស់អង្គការយូអិនអេដស៍ (UNAIDS PCB) លើកទី៥៤ ដែលគណៈប្រតិភូកម្ពុជាបានចូលរួមជាលើកទី៣ ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស បានបញ្ចប់សព្វគ្រប់ នៅរសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤។

នៅក្នុងសម័យប្រជុំលើកទី៥៤នេះ គណៈប្រតិភូកម្ពុជាបានឡើងធ្វើបទអន្តរាគមន៍ចំនួន៤ដង។ ក្នុងបទអន្តរាគមន៍នោះ ប្រតិភូកម្ពុជាបានលើកអំពីវឌ្ឍនភាពនៃការឆ្លើយតបនឹងជំងឺអេដស៍ដែលកម្ពុជាសម្រេចបានពីរគោលដៅរួចទៅហើយ លើគោលដៅ៩៥-៩៥-៩៥ទាំងបីគឺ៖ ៨៦-៩៩-៩៨។ ដើម្បីសម្រេចគោលដៅ៩៥ទីមួយដែលនៅសល់ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤កន្លងទៅ។ គោលនយោបាយនេះទាមទារឱ្យខិតខំស្វែងរកឱ្យឃើញអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ចំនួនប្រមាណជិតមួយម៉ឺននាក់ ដើម្បីឱ្យពួកគេមកធ្វើតេស្តរកមេរោគអេដស៍ និងឱ្យប្រញាប់មកទទួលសេវាថែទាំព្យាបាលទាន់ពេលវេលា។ ទន្ទឹមនឹងនេះ គោលនយោបាយក៏លើកទឹកចិត្តក្រុមយុវវ័យរួមភេទជាមួយភេទដូចគ្នា(MSM) ឱ្យមករកសេវាធ្វើតេស្តនិងទទួលអត្ថប្រយោជន៍ផ្នែកសុខាភិបាល និងគាំពារសង្គម។ គោលនយោបាយបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ បើកផ្លូវឱ្យកែសម្រួលកម្មវិធីគាំពារសង្គម ដើម្បីទាក់ទាញប្រជាជនរងហានីភ័យខ្ពស់ ឱ្យមកធ្វើតេស្តនិងទទួលសេវាថែទាំព្យាបាល។

ក្នុងពេលបច្ចុប្បន្ន កម្ពុជាកំពុងពង្រីកសេវាធ្វើតេស្តតាមបែបនវានុវត្តន៍ដូចជា៖ ការធ្វើតេស្តដោយខ្លួនឯងជាមួយនឹងការផ្តល់ថ្នាំបង្ការ(ប្រឹព)ពីចម្ងាយ (Self-testing and Tele PrEP) ផ្តល់ប្រឹពតាមរថយន្តចល័ត (Mobile Van PrEP) អន្តរាគមន៍ដែលជំរុញដោយមិត្ត (Peer Driven initiative) ការធ្វើតេស្តដែលដឹកនាំដោយសហគមន៍និងរថយន្តចល័ត(Community Led Testing and Mobile Van) ជាដើម។ កម្ពុជាបានពង្រីកការគ្របដណ្តប់កម្មវិធីប្រឹពបាន១៥ខេត្ត ក្នុងទីតាំងសុខាភិបាលចំនួន២៨ និងទីតាំងគ្រប់គ្រងដោយសហគមន៍ចំនួន១៣។ ទាក់ទងនឹងការរើសអើងនិងមាក់ងាយ កម្ពុជាប្តេជ្ញាលុបបំបាត់ការរើសអើងនិងមាក់ងាយគ្រប់ទម្រង់ចំពោះអ្នកផ្ទុកមេរោគអេដស៍ ក៏ដូចជាចំពោះប្រជាជនគន្លឹះឱ្យអស់ទាំងស្រុង ព្រោះថាការរើសអើងនិងមាក់ងាយជាឧបសគ្គចម្បងសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍។



អាសយដ្ឋាន: អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 23 885 109 និង 023 885 129
Tel: (855) 23 885 109 / 023 885 129 E-mail: info@naaa.gov.kh Website: naaa.gov.kh

នៅក្នុងបទអន្តរាគមន៍ ប្រតិភូកម្ពុជាបានចូលរួមមតិលើប្រធានបទស្តីអំពីចីរភាពកម្មវិធីអេដស៍ ដោយបានរំឭកថា កម្ពុជាបានធ្វើការវាយតម្លៃលើការត្រៀមក្នុងអន្តរកាល(Transition Readiness Assessment) នៅឆ្នាំ២០១៧ និងបានធ្វើផែនទីចង្អុលផ្លូវសម្រាប់ចីរភាពកម្មវិធីអេដស៍នៅកម្ពុជា (Cambodia HIV Sustainability Roadmap) នៅឆ្នាំ២០១៨។ ដើម្បីឆ្ពោះទៅរកចីរភាពនៃកម្មវិធីអេដស៍ កម្ពុជាមានឆន្ទៈនយោបាយក្នុងការដាក់ចេញនូវគោលនយោបាយជាតិមួយ ដែលទទួលយកតំណាងអ្នកផ្ទុកមេរោគអេដស៍និងតំណាងសហគមន៍ងាយរងគ្រោះ ឱ្យចូលរួមក្នុងយន្តការនៃការឆ្លើយតបនឹងមេរោគអេដស៍នៅគ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ប្រតិភូកម្ពុជាបានអំពាវនាវឱ្យដៃគូអភិវឌ្ឍដូចជា៖ មូលនិធិសកល ប៉ិបហ្វា(PEPFAR) ឬអង្គការយូអិនអេដស៍(UNAIDS)ជាដើម ចូលរួមពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជាឱ្យកាន់តែរឹងមាំ ដើម្បីដណ្តើមជ័យជម្នះលើមេរោគអេដស៍ឱ្យបានទាំងស្រុង។

នៅទីបញ្ចប់ តាមមតិរបស់លោកស្រី ប៉ាទ្រីស្យា អុងពីន(Patricia Ongpin) នាយិកាអង្គការយូអិនអេដស៍ប្រចាំប្រទេសកម្ពុជា ឡាវ និងម៉ាឡេស៊ី បទអន្តរាគមន៍របស់គណៈប្រតិភូកម្ពុជាលើកនេះ មិនត្រឹមតែបានបង្ហាញអំពីសមិទ្ធផលដែលសម្រេចបានដោយការខំប្រឹងប្រែងរបស់កម្ពុជា នៅលើវេទិកាពិភពលោកប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាការតស៊ូមតិដើម្បីឱ្យមានការប្តេជ្ញាតទៅទៀតនៃតួអង្គទាំងអស់ ទាំងប្រទេសសមាជិក ទាំងប្រទេសផ្តល់ជំនួយ ឆ្ពោះទៅបញ្ចប់អេដស៍ដោយជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**